00600736

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

-4-

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 09 / 2010
ម៉ោង (Time/Heure): 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/០៧-០៧-២០១០-អវតក/អបជ១០

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម និយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០

---

**សាធារណៈ**
**សេចក្តីបង្គាប់ស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ របស់អង្គបុរេជំនុំជម្រះ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH

**ជនត្រូវចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្កេកអ៊ាវ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Mahdev MOHAN
Lima NGUYEN

**សហមេធាវីការពារក្តីជនត្រូវចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE

00600737



**គឹម ម៉េងឃី**

**ម៉ុច សុវណ្ណារី**

Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN

**ឡោ ជុនធី**

**ស៊ិន សុវ៉ន**

**ហុង គឹមសួន**

**គង់ ពិសី**

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Partirck BAUDOUIN

**ជេត វណ្ណលី**

**ពេជ អង្គ**

Julien RIVET
Pascal AUBOIN

**យ៉ុង ផានិត**

Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
VEN Pov
TY Srinna
Pierre Olivier SUR
Alain WERNER
Brianne McGonigle
Karim KHAN

**ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង**

**អាង ឧត្តម**

Michael G. KARVAVAS

**ផាត់ ពៅស៊ាង**

Diana ELLIS QC

**ស សូវ៉ាន**

Jacques VERGES
Philippe GRECIANO

**ការ សាវុត្ថ**

**កង ឫទ្ធារី**

**សហចៅក្រមស៊ើបអង្កេត**

**យូ ប៊ុនឡេង**

Marcel LEMONDE

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក")កត់សម្គាល់ចំពោះការបោះពុម្ពផ្សាយនាពេលថ្មីៗនេះនៃព័ត៌មានសម្ងាត់ចេញពីឯកសារអង្គបុរេជំនុំជម្រះ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះចេញសេចក្តីបង្គាប់នេះ ស្តីពីការចាត់ប្រភេទឯកសាររបស់អង្គបុរេជំនុំជម្រះ ("សេចក្តីបង្គាប់")។

## I. **សាវតារ**

១. សម្រាប់គោលបំណងនៃសេចក្តីបង្គាប់នេះ "ឯកសារអង្គបុរេជំនុំជម្រះ" ("ឯកសារ អ.ប.ជ") សំដៅទៅលើ "កំណត់ត្រាព័ត៌មានណាមួយ"[១] ដែលត្រូវបានបញ្ជូន ឬដាក់ជូនទៅអង្គបុរេជំនុំជម្រះដោយ "បុគ្គលណាមួយដែលមានសិទ្ធិដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក"[២] ("ភាគីដាក់ឯកសារ") ដោយរួមទាំងឯកសារដែលចេញដោយអង្គភាពណាមួយរបស់ អ.វ.ត.ក ដែលអង្គបុរេជំនុំជម្រះមានយុត្តាធិការ[៣]។ សេចក្តីបង្គាប់នេះ អាចអនុវត្តស្មើគ្នាចំពោះរាល់ឯកសារ អ.ប.ជ ទាំងស្រុង ឬមួយផ្នែក[៤]។

២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ព័ត៌មានសម្ងាត់នៅក្នុងឯកសារ អ.ប.ជ ត្រូវបានបោះពុម្ពផ្សាយនាពេលថ្មីៗនេះ នៅក្នុងសារព័ត៌មាន[៥]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការបោះ

---

[១] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង អវតក/០០៤/២០០៩ មាត្រា២.គ http://www.eccc.gov.kh/khmer/cabinet/courtDoc/313/PD_Classification_Body_Kh.pdf ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ") ("កំណត់ត្រាព័ត៌មានណាក៏ដោយ (មិនថាឯកសារជាលាយ-លក្ខណ៍អក្សរ ឬជាអេឡិចត្រូនិក) ដោយរួមទាំង កំណត់ត្រាជាលាយលក្ខណ៍អក្សរ កំណត់ត្រាសោតទស្សន៍ រូបថត ប្លង់គម្រោង គំនូរ និងផែនទីនានា")។

[២] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក អវតក/០១/២០០៧/វិសោធនកម្មទី៤ មាត្រា២.២ http://www.eccc.gov.kh/khmer/cabinet/courtDoc/312/PD_Filing_Revision_4_final_Kh.pdf ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

[៣] *ឧទាហរណ៍* ដីកាសម្រេចមួយរបស់សហចៅក្រមស៊ើបអង្កេតថា សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បាន ដោយអនុលោមតាមវិធាន៧៤(២) នៃវិធានផ្ទៃក្នុង។ <u>រាល់វិធានទាំងអស់ដែលបានយោងនៅក្នុងសេចក្តីបង្គាប់នេះ គឺដកស្រង់ចេញពីវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៥ (ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០) លើកលែងតែបញ្ជាក់ឲ្យផ្ទុយពីនេះ។</u>

[៤] *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា៣.២ ដល់មាត្រា៣.៣, មាត្រា៤ដល់មាត្រា៦, មាត្រា៩។

[៥] *ឧទាហរណ៍* អត្ថបទរបស់លោក ឌូក្លាស ហ្គីលីសុន (Gouglas Gillison) "សហមេធាវីរបស់លោក នួន ជា ស្នើជាថ្មីម្តងទៀត សុំឲ្យមានការស្រាវជ្រាវលើរឿងនយោបាយ" ចេញផ្សាយនៅក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ដេលី* នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ លេខ៤៦(១) ទំព័រ២៤។ អត្ថបទរបស់លោក សេបាស្ទៀត ស្ត្រេងហ្គីអូ (Sebastian Strangio) "សហមេធាវីស្នើឲ្យមានការស៊ើបអង្កេតនៅតុលាការខ្មែរក្រហម" ចេញផ្សាយនៅក្នុង សារព័ត៌មាន

ពុម្ពផ្សាយព័ត៌មានសម្ងាត់នេះ គឺជាមូលហេតុនៃការរំឭកឡើងវិញ អំពីច្បាប់ដែលយកមកអនុវត្ត ចំពោះការចាត់ប្រភេទឯកសារ អ.ប.ជ។

៣. គោលការណ៍ដែលគាំទ្រសេចក្តីបង្គាប់នេះ គឺ "ជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំនិងកេរដំណែល"[៦]។ អង្គបុរេជំនុំជម្រះ ចាត់ប្រភេទឯកសារអ.ប.ជ ថា ជាឯកសារ "សម្ងាត់" ឬ "សម្ងាត់បំផុត" នៅដំណាក់កាលមុនអង្គសេចក្តីនៃកិច្ចស៊ើបសួររបស់តុលាការ ដើម្បីធានាឱ្យមានសុចរិតភាពនៃការស៊ើបអង្កេត និងសិទ្ធិនិងផលប្រយោជន៍របស់ភាគី។

## II. **ច្បាប់ដែលអាចយកមកអនុវត្តបាន**

៤. អង្គជំនុំជម្រះ សូមរំឭកឡើងវិញនូវចំណុចដូចខាងក្រោម ដែលដកស្រង់ចេញពី "សេចក្តីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត"[៧]៖

ក. ភាគីដាក់ឯកសារអាចស្នើថា ឯកសារណាមួយអាចត្រូវបានចាត់ប្រភេទថា ជាឯកសារ"សាធារណៈ" ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងសេចក្តី

---

*ឌឹ ភ្នំពេញ ប៉ុស្តិ៍* នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ លេខ២០(១៣០) ទំព័រ៦។ អត្ថបទរបស់ អាឌ្រាន ឡឺ ហ្គាល (Adrien Le Gal) ជាភាសាបារាំង "Le retour des 'interférences'" ចេញផ្សាយនៅក្នុងសារព័ត៌មាន *កាំបូដ្ស ស្វ័រ* នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ទំព័រ១០។ អត្ថបទរបស់លោក ឌូក្លាស ហ្គីលីសុន "រាល់បណ្តឹងឧទ្ធរណ៍មុនអង្គសេចក្តីចុងក្រោយទាំងអស់នៅក្នុងសំណុំរឿង០០២ ត្រូវបានដោះស្រាយរួចហើយនៅតុលាការ" ចេញផ្សាយនៅក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ដេលី* នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ ទំព័រ២៦។ *សូមមើលផងដែរ* ឯកសាររបស់គម្រោងយុត្តិធម៌ Open Society Justice Initiative "ការជ្រៀតជ្រែកខាងនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១០ ទំព័រ២៤ (ដោយដកស្រង់អត្ថបទរបស់ លោក ឌូក្លាស ហ្គីលីសុន 'នួន ជា ចោទប្រកាន់លោកចៅក្រម យូ ប៊ុនឡេង ថាមានលម្អៀងខាងនយោបាយ' ផ្សាយក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ដេលី* នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០)។ អត្ថបទរបស់លោក ឌូក្លាស ហ្គីលីសុន 'ព្រះរាជអាជ្ញានៅតុលាការខ្មែរក្រហម និយាយថាអ្នកសារព័ត៌មានប្រឈមនឹងការចោទប្រកាន់' ផ្សាយក្នុងសារព័ត៌មាន *ឌឹ ខេមបូឌា ដេលី* នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។

[៦] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា១.២។

[៧] ឯកសារសាធារណៈនៃសេចក្តីព្រមាននេះ (ERN ០០៥៤៨៨៨២-០០៥៤៨៨៨៥) ត្រូវបានជូនដំណឹងនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

ណែនាំអនុវត្តស្តីពីការចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងទៅនឹងសំណុំរឿង។ ទោះជាយ៉ាងនេះក៏ដោយ អង្គបុរេជំនុំជម្រះត្រូវពិចារណាថា តើចំណាត់ប្រភេទឯកសារដែលស្នើឡើងនោះ មានភាពសមស្របដែរឬទេ ហើយប្រសិនបើមិនមានភាពសមស្របទេនោះ អង្គបុរេជំនុំជម្រះត្រូវកំណត់ប្រភេទឯកសារនោះ ឲ្យបានសមស្រប រហូតទាល់តែមានដីកាដំណោះស្រាយ ហើយបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយនោះ ត្រូវបានដោះស្រាយរួច[៨]។

ខ. ជាគោលការណ៍ រាល់ឯកសារដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះទាំងអស់ គឺជាឯកសារសម្ងាត់ លុះត្រាណាមានការសម្រេចលើបញ្ហានេះ ដោយអង្គបុរេជំនុំជម្រះ។ ឯកសារទាំងនោះអាចត្រូវបានចាត់ប្រភេទផ្សេងណាមួយ ដោយអនុលោមតាមសេចក្តីសម្រេចរបស់តុលាការ[៩]។

គ. ...

ឃ. "សម្ងាត់" "មានន័យថា បើកចំហជូនចំពោះតែចៅក្រម សហព្រះរាជអាជ្ញា មេធាវីភាគីដើមបណ្តឹង មេធាវីការពារក្តី បុគ្គលិកតុលាការដែលមានសិទ្ធិ និងអ្នកទាំងឡាយណាដែលទទួលបានសិទ្ធិពិនិត្យមើលឯកសារ តាមសេចក្តីសម្រេចរបស់តុលាការជាមុន"[១០]។

ង. ភារកិច្ចរក្សាការសម្ងាត់ មានចែងដូចខាងក្រោម៖

> ជនគ្រប់រូបដែលមានសិទ្ធិពិនិត្យមើលព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ត្រូវតែគោរពគោលការណ៍នៃការរក្សាការសម្ងាត់។ ពួកគេមិនត្រូវផ្សព្វផ្សាយព័ត៌មានបែបនេះទៅឲ្យនរណាម្នាក់ លើកលែងតែអនុលោមតាមសេចក្តីណែនាំអនុវត្តនេះ។ លើសពីនេះទៀត ពួកគេមិនត្រូវប្រព្រឹត្តក្នុងរូបភាពណាក៏ដោយ ដែលនឹងបណ្តាលឲ្យលេចឮព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ដោយគ្មានការអនុញ្ញាតនោះទេ[១១]។

---

[៨] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា៣.១២។

[៩] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៥.១.ជ។

[១០] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា២.ឃ.ii។

[១១] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៨.១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

ការរំលោភបំពានលើភារកិច្ចនេះនឹងទទួលបាននូវការដាក់ទណ្ឌកម្ម ដោយអនុលោមតាមវិធានផ្ទៃក្នុង[១២]។

ច. ដោយអនុលោមតាមវិធាន៥៦(១) "បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរ ត្រូវរក្សាឱ្យបាននូវការសម្ងាត់"។

**ហេតុដូចនេះ អង្គបុរេជំនុំជម្រះសម្រេចចេញការព្រមានដូចខាងក្រោម:**

១. ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ចំពោះបុគ្គលណាមួយដែលខ្លួនបានរកឃើញថា មានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយចេតនា និងដោយដឹងឮ ដោយរួមទាំងបុគ្គលណាដែលផ្សព្វផ្សាយព័ត៌មានសម្ងាត់ ដោយមិនអនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿង ឬបុគ្គលណាដែលរំលោភបំពានលើវិធាន៥៦(១) នៃវិធានផ្ទៃក្នុង ចំពោះករណីដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរណាមួយ។

២. ដោយអនុលោមតាមវិធាន ៣៨(១)-(២) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ បន្ទាប់ពីបានចេញការព្រមានម្តងរួចហើយ អាចដាក់ទណ្ឌកម្ម ឬសម្រេចហាមឃាត់មេធាវីណាមួយពីការចូលរួមក្នុងដំណើរកិច្ចនីតិវិធី ប្រសិនបើខ្លួនយល់ឃើញថា ការប្រព្រឹត្តិរបស់មេធាវីរូបនោះ ត្រូវបានចាត់ទុកថាជាការរំខាន ឬជាការរំលោភបំពាន បង្អាក់ដំណើរកិច្ចនីតិវិធី នាំឱ្យមានការរំលោភបំពានលើដំណើរការនីតិវិធី ឬការប្រព្រឹត្តិនោះ ផ្ទុយទៅនឹងមាត្រា២១(៣) នៃកិច្ចព្រមព្រៀង។ អង្គបុរេជំនុំជម្រះ ក៏អាចបញ្ជូនបញ្ហាកំហុសវិជ្ជាជីវៈបែបនេះ ទៅកាន់ស្ថាប័នវិជ្ជាជីវៈជំនាញសមស្របណាមួយផងដែរ។

៥. អង្គបុរេជំនុំជម្រះ ក៏សូមរំឭកផងដែរនូវចំណុចដូចខាងក្រោមនេះ៖

i. ជាគោលការណ៍ សារណាដែលបានទទួល និងឯកសារដែលបានបង្កើតឡើងក្នុងអំឡុងកិច្ចស៊ើបសួរ គឺជាឯសារសម្ងាត់[១៣]។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

[១២] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា១១។

[១៣] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៥.១.ខ។

ii. ភារកិច្ចរក្សាការសម្ងាត់ទាក់ទងទៅនឹងខ្លឹមសារសំណុំរឿង ដែលត្រូវបានចងក្រងនៅក្នុងកិច្ចស៊ើបអង្កេតរបស់តុលាការ ដូចមានចែងនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង ត្រូវបន្តអនុវត្តបន្ទាប់ពីការបញ្ចប់កិច្ចស៊ើបអង្កេត ដោយអនុលោមតាមមាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ[១៤]។

iii. ក្នុងករណីដែលភស្តុតាងជាក់លាក់ណាមួយ ដែលសហចៅក្រមស៊ើបអង្កេតចាត់ទុកថាជាផ្នែកមួយនៃការស៊ើបអង្កេត មិនចំពោះថាខ្លឹមសារនៃអង្គហេតុនោះជាអ្វីទេ គឺជាព័ត៌មានសម្ងាត់[១៥]។

iv. ភារកិច្ចនៃការរក្សាភាពសម្ងាត់ ត្រូវអនុវត្តមុនពេលដែលភាគីណាមួយដាក់ឯកសាររបស់ អ.ប.ជ ទៅផ្នែកគ្រប់គ្រងតុលាការរបស់ អ.វ.ត.ក ("CMS") ឬដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ក៏ដូចជានៅពេលដែលឯកសារនោះត្រូវបានដាក់រួច និងនៅពេលដែល CMS ជូនដំណឹងស្តីពីឯកសារនោះ ដោយមានការចាត់ប្រភេទថ្នាក់ឯកសារ ដោយក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ។

v. អង្គបុរេជំនុំជម្រះ មានសមត្ថកិច្ចក្នុងការកែប្រែបញ្ជីឈ្មោះអ្នកទទួលឯកសារ ដែលប្រើដោយ CMS ដើម្បីជូនដំណឹងស្តីពីការដាក់ឯកសារ អ.ប.ជ[១៦]។

vi. អត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់បំផុត អាចត្រូវបានរៀបចំឡើងដើម្បីដាក់នៅក្នុងផ្នែកសាធារណៈនៃសំណុំរឿង តាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប។ អត្ថបទឯកសារសាធារណៈថ្មីនេះ អាចនឹងត្រូវរៀបចំឡើងតាមរយៈ៖

ក. បង្កើតច្បាប់ចម្លងពីឯកសារច្បាប់ដើម។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

---

[១៤] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៨.២។

[១៥] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៥.២។

[១៦] *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា៣.១៥ (ទាក់ទងនឹងឯកសារសម្ងាត់បំផុត)។ សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា២.ឃ.ii ("សម្ងាត់" មានន័យថាបើកចំហសម្រាប់តែ... បុគ្គលិកតុលាការដែលមានការអនុញ្ញាត និងបុគ្គលដទៃទៀតដែលត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ឲ្យចូលតុលាការតែប៉ុណ្ណោះ")។ សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា២.ក ("បុគ្គលិកតុលាការដែលមានការអនុញ្ញាត" មានន័យថា បុគ្គលិកនោះត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយ")។

ខ. កោសលុបព័ត៌មានសម្ងាត់ និង/ឬសម្ងាត់បំផុតទាំងអស់ ចេញពីឯកសារចម្លង តាមការចាំបាច់ និង

គ. បញ្ជូនច្បាប់ចម្លងដែលបានកោសលុបហើយ ទៅសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដើម្បីពិនិត្យឡើងវិញ និងសម្រេច មុននឹងដាក់ឯកសារនោះ ចូលទៅក្នុងផ្នែកសាធារណៈនៃសំណុំរឿង។

ប្រសិនបើការបង្កើតឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់បំផុតនេះធ្វើឡើងទៅតាមការស្នើរបស់ភាគីណាមួយ រាល់ការកោសលុបទាំងឡាយត្រូវធ្វើឡើងដោយភាគីស្នើនោះ ហើយត្រូវដាក់សុំការសម្រេច ដោយអនុលោមតាមមាត្រា ៩.២(គ)[១៧]។

vii. ដើម្បីផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចចាត់ចំណាត់ប្រភេទឯកសារជាថ្មី ក្នុងសំណុំរឿង។ ភាគីជាប់ពាក់ព័ន្ធនឹងត្រូវផ្តល់ឱកាសឱ្យបានដឹង និងធ្វើការឆ្លើយតប មុនមានការធ្វើសេចក្តីសម្រេចបែបនេះ ឬអំឡុងពេលដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន ដែលជាការចាំបាច់ក្នុងការការពារព័ត៌មានដែលអាចជាព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត។ នៅក្នុងករណីនេះ ភាគីពាក់ព័ន្ធនឹងសំណុំរឿង ត្រូវបានជូនដំណឹងអំពីការដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន និងអំពីសេចក្តីសម្រេចដាក់ចំណាត់ប្រភេទជាថ្មី[១៨]។ ឯកសារ ឬព័ត៌មានអាចត្រូវចាត់ប្រភេទសាឡើងវិញ (និងដាក់ទៅក្នុងផ្នែកនៃសំណុំរឿងដែលមានកម្រិតសម្ងាត់ខុសគ្នា) អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប[១៩]។

៦. អង្គបុរេជំនុំជម្រះ រំឭកបន្ថែមទៀតនូវដំណើរការនីតិវិធីដូចខាងក្រោម៖

ក. ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ[២០]។

[១៧] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៩.២ ដល់មាត្រា៩.៣។

[១៨] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា៣.១៥។

[១៩] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៩.១។

[២០] វិធាន៥៦(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា២៣។ វិធាន២៩.៤(ង) មាត្រា២៩.៥។ *សេចក្តីបង្គាប់ស្តីពីការចាត់ថ្នាក់ឯកសាររបស់អង្គបុរេជំនុំជម្រះ*

ខ. សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវធ្វើឡើងជា*អសាធារណៈ* លើកលែងតែមានចែងឲ្យផ្សេងពីនេះ[២១]។

គ. អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ[២២]។

ឃ. រាល់សេចក្តីសម្រេចដែលមានសំឡេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំងមតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍ នៃការអង្កេតបឋម ឬការស៊ើបសួរ[២៣]។

## III. **ការពិចារណា**

៧. តាមករណីសមស្រប នៅពេលដែលសម្រេចលើការចាត់ប្រភេទឯកសារ ឬការចាត់ប្រភេទឯកសារជាថ្មី នៃឯកសារអ.ប.ជ ដូចបានរៀបរាប់នៅខាងក្រោមនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាទៅលើកត្តាទាំងនេះ៖ ផលប្រយោជន៍យុត្តិធម៌ សុចរិតភាពនៃការស៊ើបអង្កេតបឋម និង/ឬ កិច្ចស៊ើបសួររបស់តុលាការ សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ សណ្តាប់ធ្នាប់សាធារណៈ តម្លាភាព និងវិធានការការពារនានាដែលអនុញ្ញាតដោយតុលាការ (“កត្តានានា”)។

៨. នៅពេលភាគីដាក់ឯកសារណាមួយ ដាក់ឯកសារ អ.ប.ជ ដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដូចជាបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងតាមវិធាន៧៤.៣(ខ) នៃវិធានផ្ទៃក្នុង ជាគោលការណ៍ អង្គបុរេជំនុំជម្រះនឹងចាត់ប្រភេទឯកសារនោះថា ជាឯកសារ “សម្ងាត់” ឬ “សម្ងាត់បំផុត” ដោយអនុលោមតាមវិធាន៥៦(១) នៃវិធានផ្ទៃក្នុង ទៅតាមឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ[២៤]។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

---

[២១] វិធាន៧៧(៥) នៃវិធានផ្ទៃក្នុង។

[២២] វិធាន៧៧(៦) នៃវិធានផ្ទៃក្នុង។

[២៣] វិធាន៧៨ នៃវិធានផ្ទៃក្នុង។

[២៤] សាលដីកាលើ “សំណើសុំបើកសវនាការដេញដោលផ្ទាល់មាត់” លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និង២៥ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៤ និង២៥) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ឯកសារ D164/4/3 កថាខណ្ឌទី៥។

៩. នៅពេលភាគីដាក់ឯកសារណាមួយ ដាក់ឯកសារ អ.ប.ជ ដែលមិនពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដូចជា ពាក្យបណ្តឹងជំទាស់ដោយចិត្តចំពោះចៅក្រម តាមវិធាន៣៤ នៃវិធានផ្ទៃក្នុង ជាគោលការណ៍ អង្គបុរេជំនុំជម្រះនឹងចាត់ប្រភេទឯកសារនោះថា ជាឯកសារ "សាធារណៈ" ដើម្បីធានាឱ្យមានតម្លាភាព[២៥] ទៅតាមឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើព័ត៌មាននៅក្នុងឯកសារ អ.ប.ជ នោះ ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ឬទាមទារឱ្យចាត់ប្រភេទក្រៅពី "សាធារណៈ" ដោយផ្អែកទៅលើការពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើកត្តានានា[២៦] អង្គបុរេជំនុំជម្រះនឹងចាត់ប្រភេទព័ត៌មាននោះ ឬឯកសារ អ.ប.ជ ទាំងមូលនោះថា ជាឯកសារ "សម្ងាត់" ឬ "សម្ងាត់បំផុត"។

១០. អង្គបុរេជំនុំជម្រះអាចចាត់ប្រភេទឯកសារអ.ប.ជណាមួយជាថ្មី ដោយផ្អែកលើការពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើកត្តានានា រហូតដល់ពេលចេញដីកាដំណោះស្រាយ ហើយបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយនោះ ត្រូវបានដោះស្រាយរួច។ អង្គបុរេជំនុំជម្រះនឹងផ្តល់ឱកាសឱ្យភាគីដាក់ឯកសារ ដាក់ការសង្កេតរបស់ខ្លួនចំពោះការចាត់ប្រភេទថ្មីនេះ ក្នុងករណីណាដែលអង្គបុរេជំនុំជម្រះសម្រេចថា អ្នកអង្កេតសត្យានុម័តមួយអាចយល់ឃើញដោយសមហេតុផល

---

សាលដីកាលើសំណើសុំការពិចារណាឡើងវិញ ចំពោះសេចក្តីសម្រេចលើសំណើសុំបើកសវនាការផ្ទាល់មាត់ លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និង២៥ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៤) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ឯកសារ D164/4/9 កថាខណ្ឌទី១៤ ដល់៣១។

២៥ ជាឧទាហរណ៍ អង្គបុរេជំនុំជម្រះបានចាត់ប្រភេទ "សាធារណៈ" ចំពោះឯកសារនៅក្នុងបណ្តឹងរបស់ អៀង សារី លើឯករាជ្យភាពរបស់ចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing (សំណុំរឿងលេខ ០០២/២០-១០-២០០៩-អវតក/កសចស (អបជ០៣) ចំពោះសាលដីកាលើសំណើរបស់ អៀង សារី ស្នើសុំឱ្យមានវិធានការសមស្រប ចំពោះសេចក្តីថ្លែងការណ៍ជាក់លាក់មួយចំនួនរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតវ៉ាពីឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ៥ លេខ ERN ០០៤០៤៥៩៥-០០៤០៤៦០១)។ នៅក្នុងករណីនេះ សំណើនោះធ្វើឡើងដោយផ្អែកទៅលើសុន្ទរកថាសាធារណៈមួយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយខ្លឹមសារសំខាន់នៃការចោទប្រកាន់ និងដំណោះស្រាយចំពោះបញ្ហានោះ មិនបានតម្រូវឱ្យមានការស៊ើបអង្កេតទៅលើយន្តការផ្ទៃក្នុងរបស់តុលាការ ឬទៅលើខ្លឹមសារនៃកិច្ចស៊ើបសួររបស់តុលាការនោះទេ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការចាត់ប្រភេទឯកសារ និងសាលដីកានោះថាជាឯកសារ "សាធារណៈ" គឺជាការសមស្របសម្រាប់ផលប្រយោជន៍យុត្តិធម៌។

២៦ *សូមមើលផងដែរ* ក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រម អ.វ.ត.ក មាត្រា៤ <http://www.eccc.gov.kh/khmer/cabinet/fileUpload/143/Code_of_judicial_KH.pdf> ("ព័ត៌មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់[ចៅក្រម] និងភាពសម្ងាត់នៃការពិភាក្សាសម្រេច")។

00600746



ថា ការចាត់ប្រភេទឯកសារឡើងវិញនេះ មានការប៉ះពាល់ដល់កត្តាណាមួយនៃកត្តានានាដូចបានរៀបរាប់ពីខាងលើ។ ទៅតាមសំណើរបស់ខ្លួន ភាគីដែលដាក់ឯកសារ នឹងត្រូវបានផ្តល់ឱ្យនូវសំអាងហេតុ សម្រាប់ការចាត់ប្រភេទឯកសារជាថ្មីនេះ ទៅតាមការសមស្រប[២៧]។

១១. អង្គបុរេជំនុំជម្រះអាចចាត់ប្រភេទព័ត៌មានដែលមាននៅក្នុងឯកសារអ.ប.ជ "សម្ងាត់" ឬ "សម្ងាត់បំផុត" ណាមួយជាថ្មីម្តងទៀតថា ជាឯកសារ "សាធារណៈ" ដោយមានជាអាទិ៍ តាមរយៈការដាក់បញ្ចូលព័ត៌មានបែបនេះ ទៅក្នុងសាលដីកា ឬសេចក្តីសម្រេចសាធារណៈណាមួយ។ នៅក្នុងករណីបែបនេះ តាមការសមស្រប អង្គបុរេជំនុំជម្រះនឹងផ្តល់ឱកាសឱ្យភាគីដាក់ឯកសារដាក់ការសង្កេតរបស់ខ្លួន ប្រសិនបើអង្គបុរេជំនុំជម្រះបានសម្រេចថា អ្នកសង្កេតសត្យានុម័តម្នាក់អាចយល់ឃើញដោយសមហេតុផលថា ការចាត់ប្រភេទសារជាថ្មីចំពោះព័ត៌មាននោះ ប៉ះពាល់ដល់កត្តាណាមួយនៃកត្តានានា[២៨]។

១២. បន្ទាប់ពីមានដីកាដំណោះស្រាយ ហើយបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយនេះត្រូវបានដោះស្រាយរួច អង្គបុរេជំនុំជម្រះអាចសម្រេច ដើម្បីផលប្រយោជន៍យុត្តិធម៌ ឱ្យមានការចាត់ប្រភេទឯកសារជាថ្មីម្តងទៀតចំពោះឯកសារអ.ប.ជ ឬព័ត៌មាន ដោយអនុលោមតាមមាត្រា៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងអនុលោមតាមមាត្រា៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ។ នៅក្នុងករណីទាំងនេះ អង្គបុរេជំនុំជម្រះនឹងផ្តល់ឱកាសឱ្យទៅភាគីដែលទទួលផលប៉ះពាល់ បង្ហាញការសង្កេតរបស់ខ្លួន ដោយអនុលោមតាមមាត្រា៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ អង្គបុរេជំនុំជម្រះនឹងជូនដំណឹងដល់ភាគីដែលរងការប៉ះពាល់ អំពីការចាត់ប្រភេទឯកសារថ្មីបណ្តោះអាសន្នណាមួយ និងអំពីសេចក្តីសម្រេចនានាស្តីពីការចាត់ប្រភេទឯកសារ។

១៣. នៅពេលដែលអង្គបុរេជំនុំជម្រះបានសម្រេចថា ការចាត់ប្រភេទឯកសារសមស្របចំពោះឯកសារអ.ប.ជ ទាំងអស់ដែលទាក់ទងនឹងបញ្ហាណាមួយថា ជាឯកសារ "សាធារណៈ"នោះ ជាទូទៅអង្គបុរេជំនុំជម្រះនឹងចេញសាលដីកា ឬសេចក្តីសម្រេច "សាធារណៈ" តែមួយប៉ុណ្ណោះលើបញ្ហានោះ។ នៅពេលដែលអង្គបុរេជំនុំជម្រះបានសម្រេចថា ការចាត់ប្រភេទឯកសារសមស្របចំពោះ

---

[២៧] *ឧទាហរណ៍* ការប្រើប្រាស់សំណើសម្រាប់ទម្រង់កែតម្រូវ។

[២៨] វិធាន៧៧(៦) នៃវិធានផ្ទៃក្នុង។ ការពិចារណាដូចគ្នាយកមកអនុវត្តចំពោះការបង្កើតសាជាថ្មីនូវសាលដីកា ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ "សម្ងាត់" ដែលដកស្រង់ព័ត៌មានចេញពីឯកសារ អ.ប.ជ "សម្ងាត់បំផុត" នោះ។

ឯកសារអ.ប.ជ ទាំងអស់ ឬមួយចំនួនដែលទាក់ទងនឹងបញ្ហាណាមួយថា ជាឯកសារ "សម្ងាត់" និង/ឬ "សម្ងាត់បំផុត"នោះ អង្គបុរេជំនុំជម្រះនឹងចេញសាលដីកា ឬសេចក្តីសម្រេច "សាធារណៈ" មួយលើបញ្ហានោះ ទៅតាមករណីសមស្រប ដោយរួមទាំង ការកោសលុបចាំបាច់នានា និងចេញសាលដីកា ឬសេចក្តីសម្រេច អ.ប.ជ "សម្ងាត់" ឬ "សម្ងាត់បំផុត" មួយទៀតលើបញ្ហានោះ[២៩]។

## IV. សន្និដ្ឋាន

១៤. រាល់បុគ្គលទាំងអស់ដែលមានសិទ្ធិដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ត្រូវចងចាំនូវកាតព្វកិច្ចរបស់ខ្លួន ដោយអនុវត្តឱ្យបានស្របទៅនឹងច្បាប់សម្រាប់ចាត់ប្រភេទឯកសារអ.ប.ជ ដោយរួមទាំង (តែមិនកម្រិតត្រឹមតែ) ឯកសារទាំងឡាយដែលបានរៀបរាប់នៅក្នុងសេចក្តីបង្គាប់នេះ។

១៥. នៅក្នុងពេលសមស្រប អង្គបុរេជំនុំជម្រះ នឹងពិនិត្យឡើងវិញទៅលើការចាត់ប្រភេទឯកសារ អ.ប.ជនានា ដែលមាននៅក្នុងសំណុំរឿង00២ ដើម្បីដកចេញនូវការចាត់ប្រភេទថា សម្ងាត់ ពីឯកសារទាំងនោះ តាមការសមស្រប ដោយអនុលោមតាមច្បាប់ដែលអាចអនុវត្តសម្រាប់ការចាត់ប្រភេទឯកសារ អ.ប.ជ ដោយរួមទាំងឯកសារទាំងឡាយដែលបានរៀបរាប់នៅក្នុងសេចក្តីបង្គាប់នេះ។

ភ្នំពេញ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១០

**ចៅក្រមអង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គីមសាន**

[២៩] សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទថ្នាក់ឯកសារ មាត្រា៩.២ ("អត្ថបទឯកសារសម្ងាត់នៃឯកសារសម្ងាត់បំផុត អាចត្រូវបានបង្កើតឡើងតាមលក្ខណៈដូចគ្នា")។